ប្រវត្តិនៃការនេសាទរបស់ព្រឹទ្ធាចារ្យ នៅខេត្តកំពង់ធំ

FACT
Sustainable Livelihoods

សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល

# ទន្លេសាបខ្ញុំ



មេសា - ២០០៥

ម.ព.ឯ.ក AIDOC
Code: 142-024
Date:
Donated by:

# ទន្លេសាបខ្ញុំ

**រៀបចំដោយ**

| | |
|---|---|
| លោក ឯម ច័ន្ទណារិទ្ធ (FACT/CWS) | លោក ស៊ុំ សុង (FYDO) |
| ក.សេង ផល្លា (FACT) | លោក ឡុង ឆាន (COP) |
| លោក ឡុង លីហ៊ួរ (ADHOC) | លោក ឈន ថៃ (WFY) |
| លោកស្រី ជុំ ចន្ទ័ពុទ្ធារី (COWS) | លោក គិត សៀប (CODEC) |
| លោក ហ៊ុយ ថុល (WFYD) | លោក កង សាអ៊ុំ (HOM) |
| លោក អ៊ុំ ថាច់ អនុស៊ីយ៍ឯក | លោក អាំ សេន (CODEC) |
| លោក ជួប ជន់ជា (OKRCD) | លោក អាំ សេន (DOCS) |

មេសា ២០០៥

# អារម្ភកថា

បឹងទន្លេសាប គឺជាប្រភពធនធានដ៏មានសារៈសំខាន់សំរាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ ហើយប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ជាពិសេសអ្នករស់នៅជនបទពឹងផ្អែកទាំងស្រុងទៅលើធនធានជលផល បន្ទាប់ពីស្រូវ។ ដោយសារបឹងទន្លេសាបបានផ្តល់នូវសារៈប្រយោជន៍ដ៏លើសលប់ ទើបអង្គការសម្ពន្ធ័ភាព ដើម្បីអភិរក្សធនធានជលផល **(FACT)** បានចុះទៅប្រមូលរឿងដើម្បីចងក្រងទុកជាឯកសារស្តីពីប្រវត្តិពិតរបស់អ្នកនេសាទនៅជុំវិញបឹងទន្លេសាប ក្នុងគោលបំណងឆ្លុះបញ្ចាំងពីតថភាពពិតនៃបឹងទន្លេសាបដែលមានទំនាក់ទំនងយ៉ាងជិតស្និតទៅជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជំនឿទំនៀមទំលាប់ប្រពៃណី ប្រវត្តិទីតាំងភូមិសាស្រ្ត។ ការសិក្សាស្រាវជ្រាវនេះត្រូវធ្វើឡើងតាមរយៈការសំភាសន៍ជាមួយមនុស្សដែលមានវ័យចំណាស់ក្នុងភូមិ ឬអ្នកដែលអាចចងចាំបានល្អពីភាពសំបូរធនធាន នៅក្នុងបឹងទន្លេសាបកាលពីអតីតកាលពីប្រវត្តិបឹងបួរជំនឿផ្សេងៗ សកម្មភាពនេសាទ ប្រវត្តិទីតាំងភូមិសាស្រ្ត ជាដើម ។

ប្រសិនជាគ្មានការប្រមូលកត់ត្រាទុកទេរឿងទាំងនេះមានការរាយប៉ាយ និងបាត់បង់នូវឯកសារមួយដ៏មានតំលៃជាក់ជាពុំខាន ដោយហេតុនេះបានជាអង្គការសម្ពន្ធ័ភាពដើម្បីអភិរក្សធនធានជលផលខិតខំស្រាវជ្រាវ និងចងក្រងពីប្រវត្តិអ្នកនេសាទក៏ដូចជាប្រវត្តិទីតាំងភូមិសាស្រ្តនៅជុំវិញបឹងទន្លេសាបដោយមានខេត្តចំនួន៥រួមមាន ខេត្តកំពង់ធំ ពោធិ៍សាត់ បាត់ដំបង កំពង់ឆ្នាំង និងខេត្តសៀមរាប។ ក្នុងការចុះប្រមូលរឿងក្រុមសម្ពន្ធ័ភាពដើម្បីអភិរក្សធនធានជលផល បានចូលរួមសហការពីបណ្តាអង្គការនានា នៅ

តាមខេត្តនីមួយៗដោយបានជួយជ្រោមជ្រែងអស់ពីកំលាំងកាយ និងកំលាំងចិត្ត ទើបអាចផលិតចេញជាកូនសៀវភៅមួយសំរាប់ទុកជាឯកសារ ដល់អ្នកដែលចាប់អារម្មណ៍ ឬអ្នកស្រាវជ្រាវបន្តទៀត ។

ជាទីបញ្ចប់ អង្គការសម្ពន្ធ័ភាពដើម្បីអភិរក្សធនធានជលផលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រជាពលរដ្ឋខេត្តទាំង៥ ដែលបានរួមសហការផ្តល់ជាកិច្ចសំភាសន៍ទាក់ទងនឹងប្រវត្តិផ្ទាល់ខ្លួនក៏ដូចប្រវត្តិផ្សេងៗ ដែលមានប្រយោជន៍សំរាប់ក្រុមការងាររបស់អង្គការយើងខ្ញុំ ជាពិសេសសូមថ្លែងអំណរគុណចំពោះអង្គការអុកស្វាមមេរិកកាំង (Oxfam America) ដែលបានផ្តល់ជាមូលនិធិសំរាប់ការសិក្សាស្រាវជ្រាវនេះ ។

ក្រុមការងារយើងខ្ញុំនឹងរង់ចាំទទួលការរិះគន់កែលំអរពីសំណាក់មិត្តអ្នកអានក៏ដូចជាប្រជាពលរដ្ឋគ្រប់រូប ដើម្បីធ្វើអោយស្នាដៃនេះកាន់តែមានលក្ខណៈប្រសើរ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០០៥

ដោយសម្ពន្ធ័ភាពដើម្បីអភិរក្សធនធានជលផល

# មាតិកា


-ប្រវត្តិបឹងបបែល ........................................ ១
-ប្រវត្តិបឹងរៀល ........................................ ៧
-ប្រវត្តិបឹងក្បាលក្របី ........................................ ១១
-ប្រវត្តិបឹងសណ្តាយ ........................................ ១៥
-ប្រវត្តិបឹងខែលមាស ........................................ ១៩
-ប្រវត្តិបឹងបន្ទះជាល ........................................ ២៤
-ប្រវត្តិឡូតិ៍បំរុង ........................................ ២៩
-ប្រវត្តិបឹងកន្សោមចាប ........................................ ៣៣
-ប្រវត្តិបឹងរាល ........................................ ៣៨
-ប្រវត្តិបឹងក្បាលព្រួស ........................................ ៤២
-ប្រវត្តិបឹងដំរីស្លាប់ ........................................ ៤៦
-ប្រវត្តិបឹងពាក់ព្រ័ទ្ធ ........................................ ៥០
-ប្រវត្តិបឹងតាពីរ ........................................ ៥៤
-ប្រវត្តិបឹងកាប់ផ្សោត ........................................ ៥៨
-ប្រវត្តិបឹងពាក់ថែប ........................................ ៦២
-ប្រវត្តិបឹងអន្ទង់ ........................................ ៦៦
-ប្រវត្តិបឹងប្រវែង ........................................ ៧១
-ប្រវត្តិបឹងផ្សោត ........................................ ៧៥
-ប្រវត្តិបឹងតាសែង ........................................ ៨០
-ប្រវត្តិបឹងភក់ ........................................ ៨៥

# ប្រវត្តិបឹងបបែល

ខេត្តកំពង់ធំ គឺជាខេត្តមួយស្ថិតនៅចំកណ្តាលនៃប្រទេសកម្ពុជា និងមានស្រុកចំនួន០៨ បើយើងធ្វើដំណើរពីខេត្តទៅភ្នំពេញ គេត្រូវឆ្លងកាត់ស្រុកបីគឺស្រុកស្ទឹងសែន ស្រុកសន្ទុក និងស្រុកបារាយណ៏។ ដោយឡែកស្រុកបារាយណ៏ ជាស្រុកមួយសំបូរទៅដោយបឹងធំជាច្រើន ដែលទទួលរបបទឹកពីបឹងទន្លេសាបនៅរដូវវស្សា ជារៀងរាល់ឆ្នាំជាក់ស្តែងដូចជា *បឹងបបែល* ។

តាមការសំភាសន៏របស់លោកតា **យ៉ិន ស៊ីម** មានអាយុ៦៨ឆ្នាំ និងមានស្រុកកំណើតនៅភូមិកងមាស ឃុំត្នោតជុំ ស្រុកបារាយណ៏ ខេត្តកំពង់ធំបានរៀបរាប់ពីជីវិតផ្ទាល់ខ្លួនថា គាត់មានកូនចំនួន៦នាក់ក្នុងនោះ មានប្រុស៣នាក់ ប្រពន្ធរបស់គាត់មានឈ្មោះ **យាយ វ៉ុធ** ។ កាលពីដើម គាត់ជាប្រជាកសិករ និងជាអ្នកនេសាទម្នាក់ដែលតែងតែទៅនេសាទនៅក្នុងបឹងបបែលនេះ តាំងតែពីតូចមក ទាំងប្រាំង និងវស្សា។ សព្វថ្ងៃនេះគាត់បានចូលរក្សាសីលនៅវត្តកងមាស ឃុំត្នោតជុំ ស្រុកបារាយ-ណ៏។ គាត់បានមានប្រសាសន៏បន្តទៀតថា បឹងបបែលជាបឹងមួយដែលស្ថិតនៅភូមិកងមាស ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដែលមានចំងាយពី



**លោកតា យ៉ិន ស៊ីម ជាប្រជាពលរដ្ឋនៅភូមិកងមាស**

ភូមិកងមាស៥គីឡូម៉ែត្រ និងចំងាយពីបឹងទន្លេសាប ប្រហែល៤០ទៅ៥០គីឡូម៉ែត្រ ហើយបើគិតពីខេត្តកំពង់ធំមានចំងាយ ៥២គីឡូម៉ែត្រ។ បឹងនេះមានរាងទ្រវែង ដែលមានបណ្តោយពីជើងទៅត្បូង និងទទឹងពីកើតទៅលិច។ កាលពីដើមឡើយ បឹងនេះមានបណ្តោយប្រវែង២គីឡូម៉ែត្រ និងទទឹង១គីឡូម៉ែត្រ។ នៅរដូវវស្សា បឹងនេះមានជំរៅជ្រៅបំផុតនោះ គឺ១៥ម៉ែត្រ និងកន្លែងរាក់ល្អម គឺប្រហែលជា ១០ ម៉ែត្រ។ នៅរដូវប្រាំងបឹងនេះជំរៅនៅកន្លែងរាក់ល្អម ប្រហែលជា៥ម៉ែត្រ ទៅ៨ម៉ែត្រ។ នៅចំកណ្តាលបឹងមានអន្លង់ធំមួយ ហើយក្នុងអន្លង់នោះមានថ្មមួយដុំធ្លាក់ជារូបគោ ដែលជានិមិត្តរូបមួយសំរាប់អោយអ្នកនេសាទមកប្រាថ្នាសុំសេចក្តីសុខ។ គាត់បានបញ្ជាក់ទៀតថា ថ្មនេះគឺស័ក្តសិទ្ធិណាស់បើគេប៉ងប្រាថ្នាចង់បានអ្វីគឺបានសំរេចដូចការប្រាថ្នា។ ក្រៅពីថ្មនេះ នៅមានវត្ថុបុរាណជាច្រើនទៀតដូចជា ចានបញ្ជុរុង ដែលមានរាងដូចជើងពាន និងសំណាញព្រមទាំងមានរបស់របរជាច្រើនទៀត។ របស់របរទាំងនេះប្រជានេសាទតែងតែរកបាន ហើយយកទៅប្រើប្រាស់ជាធម្មតាគ្មាន បង្កភាពចង្រៃដល់ពួកគាត់ឡើយ។ បឹងនេះមានប្រពន្ធ័ផ្លូវទឹក៣ មួយជាអូរ និង២ទៀត ហៅថាដៃអាវកក់ និងដៃដំរីជាន់ ព្រោះដៃនោះវាធ្លាក់ទៅដល់បឹងមួយឈ្មោះ បឹងដំរីជាន់។



ទិដ្ឋភាពបឹង បបែលមើលពីចំងាយ

ប្រពន្ធ័ផ្លូវទឹកទាំងនេះមានសារៈសំខាន់ណាស់ព្រោះទឹកនៅរដូវវស្សា ទឹកតែងតែហូរចូលមកបឹងបបែលនេះជារៀងរាល់ឆ្នាំ។ កាលពីដើមនៅក្នុងបឹងនេះ មានសត្វបបែលដ៏ធំរស់នៅ ប្រជាពលរដ្ឋដែលធ្វើដំណើរតាមបឹងនេះ តែងជួបប្រទះវាជាញឹកញាប់ ហើយវាតែងតែបង្កគ្រោះថ្នាក់ដូចជា កោសទូកមិនអោយទៅមុខ ទាល់តែនាំគ្នាធ្វើការបួងសួងសុំអង្វរដល់លោកតាម្ចាស់ទឹក ម្ចាស់ដី ទើបអាចបន្តដំណើរទៅមុខទៀតបាន។ លុះក្រោយមកទៀតមានថៅកែម្នាក់ឈ្មោះ **កែ ហាម៉ីងលី** ជាជនជាតិចិន និងជាអ្នកមានជាងគេនៅក្នុងស្រុកបារាយណ៍ បានមកធ្វើការទំនាក់ទំនងជាមួយមេភូមិ មេឃុំ ដើម្បីបង្ហូរទឹកចេញពីបឹងក្នុងគោលបំណងចាប់យកមច្ឆាជាតិ និងវត្ថុបុរាណដែលមានតំលៃនៅក្នុងបឹងនោះ។ ថៅកែនោះបានជីកព្រែកមួយចេញពីបឹងទៅស្ទឹងជីនិត ប្រវែងប្រហែលជា៣គីឡូម៉ែត្រ ឃើញដូច្នេះបងប្អូនក៏នាំគ្នាទៅបន់ស្រន់បួងសួងសុំសេចក្តីសុខពីលោកតាម្ចាស់ទឹកម្ចាស់ដី ដើម្បីកុំអោយទឹករីងពីបឹងនោះ រំពេចនោះស្រាប់តែមេឃប្រែជាខ្មៅងងឹត និងមានខ្យល់ធ្វើអោយសត្វបបែល និងត្រីតូចធំគ្រប់ប្រភេទក្នុងបឹងនោះ ផ្អើលចេញមកនៅតាមក្បែរមាត់បឹង ព្រមជាមួយភ្លៀងមួយមេយ៉ាងធំ និងមានរន្ទះបាញ់មកពីទិសខាងលិចមកកើតឈាងខាងជើងមាត់បឹង ធ្លាក់ចំអន្លង់មួយធ្វើអោយទឹកហូរចេញមកបង្កើតជាអន្លង់មួយហៅថា អន្លង់បឹងរន្ទះបាញ់ រីដៃអណ្តូង។ ចំពោះព្រែកជីកដែលថៅកែនោះបានជីកគេហៅថា ព្រែកមីងលី រហូតដល់សព្វថ្ងៃ។ ដោយឃើញស្ថានភាពដ៏អស្ចារ្យរបស់សត្វបបែល ប្រជាពលរដ្ឋក៏ហៅបឹងនោះថា បឹងបបែល រហូតមកដល់សព្វថ្ងៃនេះទៅ។ គាត់ក៏បានមានប្រសាសន៍ទៀតថា កាលពីដើម នៅជុំ